**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

# មតិផ្ដើមរបស់ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ថ្លែងក្នុងពិធីផ្សព្វផ្សាយ អំពីខ្លឹមសាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ

**ថ្ងៃពុធ ទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣**

សូមគោរពគណៈអធិបតី

សម្ដេច ឯកឧត្ដម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា សាស្ត្រាចារ្យ មន្ត្រីរាជការ និង គរុសិស្សទាំងអស់ ជាទីរាប់អាន

ជាបឋម តាងនាមគណៈប្រតិភូក្រុមប្រឹក្សាធម្មនុញ្ញ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកនាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញដែលបានធ្វើលិខិតអញ្ជើញលេខ ០១៤ មគភ.រភ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣ ឱ្យក្រុមប្រឹក្សាធម្មនុញ្ញមកអប់រំផ្សព្វផ្សាយខ្លឹមសាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនាថ្ងៃនេះ ហើយក៏សូមស្វាគមន៍យ៉ាងកក់ក្ដៅចំពោះវត្តមាន ឯកឧត្ដម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ដែលមានវត្តមាននៅពេលនេះ។ ខ្ញុំសូមអនុញ្ញាតជម្រាបថា នេះជាលើកដំបូងហើយដែលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ បានអញ្ជើញក្រុមប្រឹក្សាធម្មនុញ្ញមកចូលរួមការចែករំលែកចំណេះដឹង និង ពិសោធន៍ពាក់ព័ន្ធនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

មុននឹងចូលដល់ប្រធានបទ ខ្ញុំសូមអនុញ្ញាតឧទ្ទេសនាមសមាសភាពគណៈប្រតិភូក្រុមប្រឹក្សា-ធម្មនុញ្ញ វត្តមានថ្ងៃនេះ មាន ..........................................................................................

ជាបន្ត ខ្ញុំមានកិត្តិយសជម្រាបពីប្រវត្តិរដ្ឋធម្មនុញ្ញរបស់ប្រទេសយើងដូចតទៅ ប្រទេសកម្ពុជាចាប់ផ្ដើមមានរដ្ឋធម្មនុញ្ញតាំងពីឆ្នាំ១៩៤៧ មកម្ល៉េះ ហើយបានផ្លាស់ប្ដូរជាបន្តបន្ទាប់អស់ចំនួន ០៦ លើកមកហើយ ទៅតាមការផ្លាស់ប្ដូររបបនយោបាយមានដូចតទៅនេះ ÷

ទី១ រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ពីឆ្នាំ១៩៤៧ ដល់ ឆ្នាំ១៩៧០ ត្រូវបានធ្វើវិសោធនកម្មចំនួន ១២ លើក និង ចែកចេញជា ១២ ជំពូក និង មាន ១២២ មាត្រា ។

ទី២ រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ពីឆ្នាំ១៩៧០ ដល់ ឆ្នាំ១៩៧៥ ចែកចេញជា ១១ជំពូក និង មាន ១២១ មាត្រា និង មានមាត្រាអវសានមួយផង ។

ទី៣ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ចែកចេញជា ១៦ជំពូក និង មាន ២១ មាត្រា ។

ទី៤ រដ្ឋធម្មនុញ្ញសាធារណរដ្ឋប្រជាមានិតកម្ពុជា ពីឆ្នាំ១៩៧៩ ដល់ ឆ្នាំ១៩៨៩ ចែកចេញជា ១០ជំពូក និង មាន ៩៣ មាត្រា ។

ទី៥ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ពីឆ្នាំ១៩៨៩ ដល់ ឆ្នាំ១៩៩៣ ចែកចេញជា ១០ជំពូក និង មាន ៩៣មាត្រា ។

ទី៦ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៩៣) នៅក្នុងនីតិកាលទី១ នៃរដ្ឋសភា (១៩៩៣-១៩៩៨) រដ្ឋធម្មនុញ្ញនេះចែកចេញជា ១៤ជំពូក និង មាន ១៣៩មាត្រា ។ ឆ្លងពីរដ្ឋសភានីតិកាលទី ១ រហូតដល់រដ្ឋសភានីតិកាលទី ៤ បច្ចុប្បន្នយើងឃើញថាមានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញចំនួន ០៦ លើក ព្រមទាំងមានច្បាប់ធម្មនុញ្ញបន្ថែមមួយទៀត ដែលទាំងអស់ខាងលើនេះគឺសុទ្ធតែផ្អែកលើភាពចាំបាច់របស់ព្រះរាជាណាចក្រកម្ពុជា (សុភាសិតបារាំងមួយថា nécessité fait loi) ញ៉ាំងឱ្យរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ចែកជា ១៦ ជំពូក និង មាន ១៥៨ មាត្រា ។

ផ្អែកតាមរបៀបវារៈព្រឹកនេះ យើងលើកយករដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា និង សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ មកធ្វើជាប្រធានបទសម្រាប់ស្វែងយល់ ដោយមានលោកជំទាវ **ស៊ុំ នីផា** សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកឧទ្ទេសនាម ។

ខ្ញុំមានកិត្តិយស ជម្រាបជូនអំពីស្ថាប័នក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នកំពូលមួយ ឯករាជ្យ និង អព្យាក្រឹត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និង ត្រូវបានបង្កើតឡើងដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ក្រុមប្រឹក្សាធម្មនុញ្ញ ចាប់ផ្តើមបំពេញការងាររបស់ខ្លួនពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ១៩៩៨ នៅអគារ "ស" ក្នុងបរិវេណវិមានរដ្ឋចំការមន។

ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ក្នុងក្របខ័ណ្ឌនៃ

ការត្រួតពិនិត្យធម្មនុញ្ញភាព ព្រមទាំងមានសិទ្ធិពិនិត្យ និង សម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា។

ក្រុមប្រឹក្សាធម្មនុញ្ញ ថ្វាយមតិព្រះមហាក្សត្រចំពោះសេចក្តីស្នើទាំងឡាយដែលសុំធ្វើការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ។ ការសើរើ និង វិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់ក្នុងកាលៈទេសៈប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ឬ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ ប្រការដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចមិនអាចសុំកែប្រែបានជាដាច់ខាត ។

ខ្ញុំសូមគូសបញ្ជាក់ថា ច្បាប់ និង សេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។ ការអនុម័តទាំងឡាយណារបស់រដ្ឋសភា ដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំឱ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ប្រទេសជាតិ នឹងត្រូវចាត់ទុកជាអសារសូន្យ។ ក្រុមប្រឹក្សាធម្មនុញ្ញ ជាអង្គការតែមួយគត់ដែលមានសមត្ថកិច្ចសម្រេចអំពីមោឃភាពនេះ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ គឺជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

ការបង្កើតស្ថាប័ននេះឡើង គឺដើម្បីរួមចំណែកក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស ការកសាងនីតិរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជានៃយើង។

ខ្ញុំសង្ឃឹមថា ពិធីផ្សព្វផ្សាយក្នុងថ្ងៃនេះ អាចចាត់ទុកជាវគ្គរៀនសូត្រខ្លីមួយដែលអាចនាំឱ្យមានការយល់ដឹងមួយកម្រិតថែមទៀតអំពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និង អំពីសមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរួមគ្នាគោរព និង ប្រតិបត្តិតាមដូចបទប្បញ្ញត្តិនៃវាក្យខណ្ឌទី១ នៃមាត្រា ៤៩ នៃរដ្ឋធម្មនុញ្ញចែងថា *"ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និង គោរពច្បាប់* ។"

ជាទីបញ្ចប់ ខ្ញុំសូមថ្វាយព្រះពរ និង ជូនពរដល់សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ដែលចូលរួម សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

បន្តទៅនេះ ខ្ញុំសូមអនុញ្ញាតដឹកនាំកម្មវិធី ដោយសូមអញ្ជើញលោកជំទាវ **ស៊ុំ នីផា** សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ ធ្វើបទឧទ្ទេសនាម។

**សូមអរគុណ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

# មតិរបស់ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ថ្លែងក្នុងពិធីបិទការផ្សព្វផ្សាយ អំពីខ្លឹមសាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ

**ថ្ងៃពុធ ទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣**

សូមគោរពគណៈអធិបតី

សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ជាសាស្ត្រាចារ្យ បុគ្គលិកសិក្សា និង គរុសិស្សទាំងអស់ ជាទីរាប់អាន

អស់រយៈពេលពេញមួយព្រឹកថ្ងៃនេះ ពិធីផ្សព្វផ្សាយខ្លឹមសាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និង សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ បានប្រព្រឹត្តទៅយ៉ាងសកម្មតាមរបៀបវារៈដែលបានគ្រោងទុក ។

ក្នុងនាមគណៈអធិបតី ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅសាជាថ្មី ចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ទាំងអស់ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ មកចូលរួមក្នុងពិធីនេះ ។ ព្រមជាមួយនេះ ខ្ញុំសូមថ្លែងនូវការកោតសរសើរដ៏ស្មោះចំពោះអស់លោក លោកស្រី អ្នកនាងកញ្ញា ចំនួន ... រូប ដែលបានតាំងសំណួរឱ្យគណៈប្រតិភូយើងខ្ញុំឆ្លើយពន្យល់ ក្នុងគោលបំណងរៀនសូត្រ យល់ដឹងអំពីរដ្ឋធម្មនុញ្ញនៃយើង និង សមត្ថកិច្ចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

រំលឹកឡើងវិញនូវស្ថានភាពនយោបាយ សង្គម សេដ្ឋកិច្ច កាលពីឆ្នាំ១៩៩៣ ពេលនោះមាតុភូមិយើង បានជួបប្រទះការលំបាកស្មុគស្មាញខ្លាំងណាស់ ។ ប៉ុន្តែដោយសារមានការស្រុះស្រួលគ្នារវាងថ្នាក់ដឹកនាំជាន់ខ្ពស់របស់គណបក្សធំទាំងបី ដែលមានអាសនៈក្នុងសភាធម្មនុញ្ញ និង ដោយមានឆន្ទៈតម្កល់ឧត្តមប្រយោជន៍ជាតិ និង ប្រជាជនជាធំ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដូចលោកជំទាវ **ស៊ុំ នីផា** បានឧទ្ទេសនាមនូវខ្លឹមសារជាសារវន្តជូនរួចហើយ ។

តាមការយល់ដឹងផ្ទាល់របស់ខ្ញុំ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ទោះបីធ្វើឡើងក្នុងរយៈពេលបីខែក៏ពិតមែន ក៏ប៉ុន្តែជារដ្ឋធម្មនុញ្ញមួយមានខ្លឹមសារល្អប្រពៃ ពីព្រោះជារដ្ឋធម្មនុញ្ញប្រសូត្រចេញពីការបង្រួបបង្រួមផ្សះផ្សាជាតិ និង បានចែងសព្វគ្រប់អំពីការគោរពសិទ្ធិមនុស្ស សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិស្ត្រី សិទ្ធិកុមារ បានធានាការអនុវត្តតាមលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ដោយឥតកែប្រែ បានចែងថា អំណាចទាំងអស់ជារបស់ប្រជារាស្ត្រ ប្រជារាស្ត្រប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និង សាលាជម្រះក្តី តាមគោលការណ៍ប្រជាធិបតេយ្យតំណាង បានប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែលព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែមិនកាន់អំណាចឡើយ ដោយឥតកែប្រែ ។ យើងអាចសន្និដ្ឋានថា យើងមានច្បាប់គោលមួយល្អហើយ បើប្រៀបធៀបទៅនឹងបណ្តាប្រទេសនៅលើពិភពលោក ។ ដូច្នេះ ករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវបន្តរៀនសូត្រ ស្វែងយល់ឱ្យអស់នូវខ្លឹមសាររដ្ឋធម្មនុញ្ញ រួបរួមគ្នាគោរពប្រតិបត្តិតាម រដ្ឋធម្មនុញ្ញ គោរពច្បាប់ និង លិខិតបទដ្ឋានទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ។ ពាក្យថា គោរពរដ្ឋធម្មនុញ្ញ និង ច្បាប់ គឺគោរពទាំងពាក្យពេចន៍ គោរពទាំងខ្លឹមសារទាំងអស់ ។ " ធ្វើរដ្ឋធម្មនុញ្ញ ធ្វើច្បាប់លិខិតបទដ្ឋាន ជាការលំបាកហើយ ប៉ុន្តែដំណើរការអនុវត្តរដ្ឋធម្មនុញ្ញ ការអនុវត្តច្បាប់លិខិតបទដ្ឋាន វាពិតជាជួបការលំបាកមួយទៀតនៅលើផ្លូវមួយវែងឆ្ងាយ ដោយមូលហេតុអត្តនោម័ត និង មូលហេតុសត្យានុម័ត " ។ ដូច្នេះទាមទារឱ្យមានការព្យាយាម ការអត់ធ្មត់ ទស្សនៈគ្រប់ជ្រុងជ្រោយ ផ្អែកលើមូលដ្ឋានគតិយុត្ត មុនធ្វើការសម្រេចប្រព្រឹត្តអំពើណាមួយដើម្បីឱ្យស្របតាមរដ្ឋធម្មនុញ្ញ ស្របតាមច្បាប់ បទបញ្ជា និង ក្រមសីលធម៌ ព្រមទាំងស្របតាមច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នរួចហើយ ។ យើងគួរអនុវត្តពាក្យស្លោកមួយថា "អ្នកចេះច្បាប់ច្រើនបង្រៀនអ្នកចេះច្បាប់តិច អ្នកចេះច្បាប់តិចបង្រៀនអ្នកមិនចេះច្បាប់សោះ" ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរគណៈអធិបតី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ**